01110252

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 23 / 06 / 2015
ម៉ោង (Time/Heure): 15:20
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

E351/1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**អង្គជំនុំជម្រះសាលាដំបូង** **សាធារណៈ / Public**

ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១៥

**ផ្ញើជូន៖** **ភាគីទាំងអស់ក្នុងសំណុំរឿង ០០២**

**ពី៖** **ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**ចម្លងជូន៖** **លោក/លោកស្រីចៅក្រម និង មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង**

TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E.C.C.C * C.E.T.C.

**កម្មវត្ថុ៖** **សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំកោះហៅសាក្សី 2-TCW-896 ដើម្បីជំនួសសាក្សី 2-TCW-912 ពាក់ព័ន្ធនឹងអង្គហេតុទំនប់ ១ មករា សំណុំរឿង ០០២/០២**

១. អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណើមួយដែលបានដាក់ដោយសហព្រះរាជអាជ្ញានៅថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៥ សុំកោះហៅសាក្សី 2-TCW-896 ដើម្បីជំនួសសាក្សី 2-TCW-912 បើទោះជាសាក្សី 2-TCW-926 អាចមកផ្តល់សក្ខីកម្មបានក៏ដោយ (ឯកសារ E351)។

២. អង្គជំនុំជម្រះកត់សម្គាល់ថា សាក្សី 2-TCW-896 ស្ថិតនៅក្នុងបញ្ជីឈ្មោះសាក្សីដើមរបស់សហព្រះរាជអាជ្ញា (ឯកសារ E9/4) តែក្រោយមកត្រូវបានដកចេញ ហើយបានស្នើសុំដាក់ជំនួសសាក្សីពីរនាក់ផ្សេងវិញ គឺ សាក្សី 2-TCW-851 និង សាក្សី 2-TCW-887 (ឯកសារ

E307/3/2 កថាខណ្ឌ ៦៤) ដោយសាក្សីទាំងពីរនេះត្រូវបានអង្គជំនុំជម្រះកោះហៅឱ្យមកផ្តល់សក្ខីកម្ម (*សូមមើល* ប្រតិចារឹកសវនាការថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១៥, ប្រតិចារឹកសវនាការថ្ងៃទី ០៤ ដល់ទី ០៥ ខែ មិថុនា ឆ្នាំ ២០១៥)។

៣. នៅថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៥ អង្គជំនុំជម្រះបានជូនដំណឹងដល់ភាគីថា អង្គជំនុំជម្រះបានទទួលព័ត៌មានពីអង្គភាពគាំពារសាក្សី និង អ្នកជំនាញ (WESU) ដែលបញ្ជាក់ថា សាក្សី 2-TCW-896 បានទទួលមរណភាពហើយ (ប្រតិចារឹកសវនាការថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៥ ទំព័រ ៣៣ ដល់ ៣៤ (ភាសាអង់គ្លេស))។ នៅថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១៥ អង្គភាពគាំពារសាក្សី និង អ្នកជំនាញ បានទទួលច្បាប់ដើមនៃសំបុត្រមរណភាពរបស់សាក្សី 2-TCW-896 ដែលត្រូវបានដាក់ក្នុងសំណុំរឿង (ឯកសារ E29/471; ឯកសារ E29/471.1)។ ហេតុដូច្នេះ អង្គជំនុំជម្រះចាត់ទុកសំណើសុំរបស់សហព្រះរាជអាជ្ញា ជាអាសារបង់។

៤. អនុស្សរណៈនេះជាចម្លើយតបផ្លូវការរបស់អង្គជំនុំជម្រះទៅនឹងឯកសារ E351។